00204379

ឯកសារ/N° A 108

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 07 / 2008
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

## អនុស្សរណៈផ្ទៃក្នុង

ថ្ងៃទី ១៥ ខែ កក្កដា ២០០៨

**ជូនចំពោះ៖** លោកប្រធានមន្ទីរឃុំឃាំងនៃ អ.វ.ត.ក

**យោង** ៖ លិខិតស្នើសុំជួបសួរសុខទុក្ខ ជនជាប់ឃុំ **នួន ជា** របស់ គ្រីស្ទ័រហ្វ័រ ឡាប៉ែល

**ពី** ៖ **លោក យូ ប៊ុនឡេង**

**លោក** Marcel LEMONDE

សហចៅក្រមស៊ើបអង្កេត

Declassified to Public
06 September 2012

**កម្មវត្ថុ** ៖ ការជួបសួរសុខទុក្ខជាមួយជនជាប់ឃុំ

ដោយរង់ចាំការអនុម័តវិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើង សូមអោយលោកប្រធានជួយសម្រួលដល់ការស្នើសុំសួរសុខទុក្ខជនជាប់ឃុំ ក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

១- ការស្នើសុំសួរសុខទុក្ខរបស់ជនដែលធ្លាប់ត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេតរួចហើយ ដូចជាករណីរបស់លោក គ្រីស្ទ័រហ្វ័រ ឡាប៉ែល ខាងលើ មិនចាំបាច់មានការអនុញ្ញាតជាថ្មីរបស់សហចៅក្រមស៊ើបអង្កេតឡើយ។ ក្នុងករណីនេះ លោកប្រធានមន្ទីរឃុំឃាំងអាចអនុញ្ញាតការសួរសុខទុក្ខនេះបាន ប៉ុន្តែ ត្រូវជូនដំណឹងជាមុនអំពីការសួរសុខទុក្ខនេះមកសហចៅក្រមស៊ើបអង្កេត ដែលអាចសម្រេចផ្សេងពីនេះនៅក្នុងករណីចាំបាច់។

២- រាល់សំណើសុំសួរសុខទុក្ខរបស់ជនដែលមិនធ្លាប់ទទួលបានការអនុញ្ញាតពីសហចៅក្រមនៅឡើយ ពាក្យសុំសួរសុខទុក្ខនោះត្រូវដាក់មកការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីទទួលការអនុញ្ញាតជាមុនសិន។

ការជួបសួរសុខទុក្ខខាងលើត្រូវគោរពទៅតាមលក្ខខណ្ឌ និង នីតិវិធីទូទៅដែលតម្រូវដោយរដ្ឋបាលគ្រប់គ្រងមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អាស្រ័យហេតុដូចនេះ សូមលោកប្រធានជួយសម្រួលក្នុងកិច្ចការនេះតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងអនុស្សរណៈនេះ។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA